# ការសម្ភាសរបស់អ៊ិម គាង

កៈអ្នកសម្ភាសឈ្មោះ កុយសុភី ខៈអ្នកត្រូវគេសម្ភាសឈ្មោះអ៊ិមគាង

## ពត៌មានសង្ខេបរបស់អ៊ិម គាង

អ៊ិមគាងមានអាយុ៦៨ឆ្នាំ! កើតនៅក្នុងពាមក្នុង ឃុំព្រែកក្របៅ ស្រុកកងមាស ខេត្តកំពង់ចាម។អ៊ីមានបងប្អូនស្លាប់នៅសម័យប៉ុលពត៣នាក់។ ក្រោយពេលដាច់សម័យប៉ុលពតអ៊ីបានមកស្រុកកំណើតធ្វើចំការដាំបន្លែលក់ក្រោយមកអ៊ីបានចូលធ្វើការនៅសមាគមន៍ភូមិឃុំ រហូតដល់បានឡើងជាអនុប្រធានសមាគមន៍ភូមិឃុំ ទោះបីជាអ៊ីអត់មានរៀនសូត្រ តែអ៊ីអាចចេះអាននិងសរសេរភាសាខ្មែរបានបន្តិចបន្តួចនិងមានគំនិតល្អៗ។

កៈ ចាសខ្ញុំជម្រាប់រលឹកអ៊ីតើសព្វថ្ងៃនេះអ៊ីសុខសប្បាយទេ?

ខៈ សុខសប្បាយទេ!

កៈ ចាស ខ្ញុំឈ្មោះកុយសុភីបានមកធ្វើការសម្ភាសអ៊ីនៅឆ្នាំចរ ឯកស័ក ២៥៦២ខែមិគសិ ៩កើតត្រូវនឹងថ្ងៃអាទិត្យទី១៦ខែធ្នូ២០១៨។ នាមត្រកូលនឹងនាមខ្លួនរបស់អ៊ីឈ្មោះអ្វី?

ខៈ នាមត្រកូលនឹងនាមខ្លួនឈ្មោះ អ៊ិមគាង!

កៈ ចាសតើឈ្មោះហ្នឹងអ្នកណាជាអ្នកដាក់អោយអ៊ី?

ខៈ ឪពុក!

កៈ អើ! ឈ្មោះហ្នឹងតើមានអត្ថន័យយ៉ាងដូចម្តេច?

ខៈ ឈ្មោះនេះគឺសមរម្យហើយ

កៈ សមរម្យល្អហើយណាអ៊ី!

ខៈ អឺម! សមរម្យល្អហើយ!

កៈ ចឹងអ៊ីមានតែឈ្មោះនេះអត់ដែរដូរទេ?

ខៈ អត់មានដែរដូរទេ មានតែឈ្មោះនឹងតាំងពីកើតកំណើតមកតែម្តង។

កៈ អ៊ីមានសញ្ជាតិជាអ្វី?

ខៈ សញ្ជាតិខ្មែរយើង!

កៈ ចាសអ៊ីកើតនៅថ្ងៃខែឆ្នាំណា?

ខៈ អត់ចាំសោះ!

កៈ ហើយចុះឆ្នាំខ្មែរមានបានចាំដែស?

ខៈ ឆ្នាំខ្មែរយើងក៏អត់ចាំដែរនុងណា!

កៈ ចុះមកដល់ពេលឥឡូវនេះអាយុប៉ុន្មានហើយ?

ខៈ អាយុបាន៦៨ឆ្នាំហើយ

កៈ ៦៨ហើយ

ខៈ ចាស!

កៈ មូលហេតុអ្វីអ៊ីអត់ចាំថ្ងៃខែឆ្នាំខ្លួនឯងចឹង?

ខៈ អត់ចាំផងព្រោះអីនៅតូច!

កៈ ឪពុកម្តាយគាត់អត់ប្រាប់ដល់យើងដែស?

ខៈ ឪពុកម្តាយគាត់អត់ប្រាប់ផង!
កក់នៅបញ្ជីជាតិតែបញ្ជីជាតិនុងមិនដឹងថាទៅឯណាទៅនែអស់ផងទៅ!

កៈ ចាស

ខៈ ចា

កៈ ទីកន្លែងអ៊ីកើតតើនៅកន្លែងភូមិឃុំស្រុកណា?

ខៈ នៅកន្លែងរស់នៅសព្វថ្ងៃតែម្តង! នៅពាមក្នុងហ្នឹង។

កៈ ចាសចឹងអ៊ីនិយាយទៅកើតនៅក្នុងភូមិ?

ខៈ កើតនៅក្នុងពាមក្នុង ឃុំព្រែកក្របៅ ស្រុកកងមាស ខេត្តកំពង់ចាម។

កៈ ចាស!នាមត្រកូលនិងនាមឈ្មោះរបស់ឪពុកអ៊ីតើមានឈ្មោះអ្វី?

ខៈ ឪពុកគាត់ឈ្មោះហ្នឹងហើយ តាអ៊ិមហ្នឹងហើយ។

កៈ តែដាក់នាមត្រកូលគាត់?

ខៈ នាមត្រកូលគាត់ឈ្មោះ ទិត្យអ៊ិម។

កៈចាគាត់ស្លាប់ហើយមកដល់ឥឡូវ?

ខៈ ស្លាប់ហើយ

កៈ តើគាត់ស្លាប់ដោយសារអ្វី?

ខៈ ស្លាប់ដោយសារតែជំងឺនោះទេ!

កៈ តើគាត់ស្លាប់នុងអាយុប៉ុន្មានដែរ?

ខៈ អូ! កាលគាត់ស្លាប់នុងមិនដឹងថានៅអាយុប៉ុន្មាននោះទេនេះ! មើលដូចជានៅ៨០ជាង ដូចជានៅ៨៣ ដែលស្លាប់នុងណា។

កៈ តែមានបានដឹងថាគាត់បានចេះអក្សរខ្មែរដែស?

ខៈ អូស គាត់បានចេះច្រើនណាស់គាត់រៀនបានច្រើន។

កៈ ចុះគាត់រៀនបានត្រឹមថ្នាក់ទីប៉ុន្មាន?

ខៈ មិនបានដឹងថាគាត់រៀនបានដល់ថ្នាក់ទីប៉ុន្មាននោះទេដឹងថាគាត់ចេះច្រើន គាត់ធ្វើជាជន្ទុកនោះ។

កៈ តើធ្វើជន្ទុកនុងយ៉ាងម៉េច?

ខៈ ហាក់! ធ្វើដូចជាស្មានយើងនុងណា!

កៈ ស្មាន

ខៈ នុងហើយ

កៈ ហើយចុះបានម្ហូបអី បានបង្អែមអីទៀតដេស?

ខៈ អូម្ហូបអីគ្មានទេ បង្អែមអីនោះ បើសិនជាបានម្ហូបត្រីឆ្អើរនោះគ្រាន់បើ។

កៈ តើមានម្ហូបអីគេខ្លះអ៊ីតើមានម្ហូបអ្វីខ្លះ?

ខៈ អឹម! ម្ហូបនុងមានដូចជាស្ងោរទៅ ម៉ាអាទិត្យនុងគេធ្វើបង្អែមបាន១ដងចឹងទៅ បើសិនជាគិតទៅវាវេទនាណាស់!! ក្មួយអើយ!

កៈ ចឹងការងារ!

ខៈ ការងារគេអោយយើងទៅរែកដី!

កៈគេអោយយើងទៅធ្វើរួមគ្នា?

ខៈ រួមគ្នារែកដី

កៈ ចាសចឹងពេលយើងហូបបាយអីនុងហូបរួចគ្នាដែរ?

ខៈ ហូបរួមគ្នាដែរ!

កៈ ចុះកន្លែងដែរយើងហូបនុងគេហៅឈ្មោះអី?

ខៈ មានរោងគេ! ១ ដូចជានៅឯខាងតាកុតនេះ !

កៈ ដូចជារែកដីនៅតាកុតនុងគេធ្វើរោង?

ខៈ រែកដីនៅតាកុតនុង

កៈ ចាស! ចឹងរែកដីនៅតាកុតនុងគេធ្វើរោងចឹងហោសអ៊ី?

ខៈ ហ្នឹងហើយគេធ្វើរោង!

កៈ ដល់ពេលគេធ្វើរោងចឹងទៅគេ
ពេលហូបបាយនុងគេបានយកបាយយកមកអោយពិសារហោស?

ខៈ អត់នោះទេ គេបានហូបនៅនឹងរោងយើងដេកនុងណា។

កៈ ចាសឡើងមកហូបបាយនៅនឹងរោងនុងទៅ?

ខៈ ហ្នឹងហើយ!

កៈ ចឹងបានមានចុងភៅអីគេធ្វើ?

ខៈ ហ្នឹងហើយបានចឹងត្រឹមត្រូវនុងទៅ!

កៈ ចាសដល់ពេលយើងបានធ្វើការងារអីចប់ហើយ
ហូបបាយអីចប់ហើយយើងទៅគេងនៅឯណាវិញ?

ខៈយើងបានមកសម្រាកនៅឯរោងអាហារនុង។

កៈ ចឹងនៅរោងបាយនុង!

ខៈ អឺ! នៅរោងបាយនៅតាកុតនុង!

កៈ ហើយចុះភួយខ្នោយ?

ខៈ អូអានុងយើងជាអ្នកយកខ្លួនយើងទៅ!

កៈ ចឹងកាលនុងមានដែរ គេអោយយើងយកទៅ?

ខៈ ហ្នឹងហើយគេអោយយើងយកទៅមានខ្នោយភួយមុងអី យកទៅដេកដោយខ្លួនយើងទៅ។

កៈ ហើយចំណែកឯសំលៀកបំពាក់អី?

ខៈ ស្លៀកខ្មៅ! ពេលនៅថ្ងៃនុងគេអោយរែក៣ម៉ែត្រដែរ។

កៈ ចុះបាយអីគេអោយពិសារបានគ្រាប់គ្រាន់ដែសអ៊ី?

ខៈ បាយអីបានគ្រាប់គ្រាន់!

កៈ ចាស!

ខៈ តែនៅភូមិយើងនេះតើវាវេទនា កាលពីមុនដំបូងនោះអ៊ីចូលនៅខាងព្រៃកកណ្ដាលណា ដល់ពេលមើលទៅវាលំបាកពេក ហូបបាយជាមួយនឹង លាយព្រលិតត្រកួនអី តែមែនទែនទៅធ្មេញអីឡើងខ្មៅអស់ហើយ ។

កៈ ចាស

ខៈ ហើយដល់ចឹងទៅអ៊ីបានរត់ទៅចូលនេះទៅ!

កៈ ចាស

ខៈ បានចូលចល័តចឹងទៅ ដល់ពេលមកអ៊ីប្រាប់ដល់ក្មួយឯង ចុះតែអ្នកអត់បាយអីក៏មានដែរ ដល់ពេលចឹងអ៊ីបានរកបាយ ទៅស៊ីនៅអូកណ្ដុរនោះ ព្រោះអីមានពួកម៉ាក់(មិត្តភក្តិ) វាអ្នកអោយ។

កៈ ចឹងចិត្តគេល្អ

ខៈ ហ្នឹងហើយវាអោយតែមកដល់ភូមិនេះគេមិនអោយស៊ីនោះទេ!

កៈ ហឹម

ខៈ ចឹងបានថាវាវេទនាណាស់ក្មួយអើយកាលនៅជំនាន់ប៉ុលពតនោះ។

កៈ ចាស!

ខៈ បើសិនជាឥឡូវនេះមានជំនាន់ប៉ុលពតមានទៀត អ៊ីងាប់មុនគេហើយ។

កៈ ចាស

ខៈចុះបើសិនជាចឹងណា!

កៈ ចាស!រួចចឹងទៅអ៊ីដូចថាពេលគេអោយរែកដីនុងចេះតែរែករួចទៅ?

ខៈ ចេះតែខំប្រឹងទៅ

កៈ អត់មានបានជួបផលលំបាកអីដូចថាយើងអស់កំលាំងឈឺអី មេការអីគេស្តីអោយដេសអ៊ី?

ខៈ ស្តីអោយណា!

កៈ ចាស

ខៈ ដល់ពេលយើងឈឺចឹងសុំគេសំរាកដល់ពេលសុំគេសំរាកចឹងគេអោយ
ច្រលក់ខោអាវអីដាក់ហាល ដែលជាខោអាវចល័តនុង។

កៈ ច្រលក់យ៉ាងម៉េច?

ខៈ យកខោអាវយើងទៅច្រលក់នៅបុកខ្លៀទៅ!

កៈ អូយកទៅច្រលក់ចេញពណ៌ខ្មៅព្រោះអីឯសណ្ឋានគេពណ៌ខ្មៅចឹងណាអ៊ី?

ខៈ ហ្នឹងហើយ! នេះប្រាប់ក្មួយឯងទៅ នៅពេលអី  ឈឺណាចឹងបានថា
ឈឺហើយសម្រាកនៅស្បៀមនោះអត់មានទេ!

កៈ ចឹងអោយទៅសម្រាកនៅពេទ្យអីអត់មានទេ?

ខៈ អត់ទេ!

កៈ ចឹងដល់ពេលឈឺអីអត់មានអីគេមើលនោះទេ?

ខៈ អត់មាននោះទេ ដល់ពេលឈឺខ្លាំងគេបានបញ្ជូនទៅពេទ្យនេះ ពេទ្យនៅនាំក្រូចយើងនេះ។

កៈ អូនៅវត្តនាំក្រូចនេះហេស?

ខៈ ចាសហ្នឹងហើយ!បើសិនជាយើងឈឺខ្លាំង
ហើយបើសិនជាយើងឈឺស្រាលតែមើលទៅល្មមៗនោះគឺនៅទៅ!

កៈ ចឹងបានថ្នាំគេអោយអ៊ីយកមកលេបអីទៅនៅផ្ទះទៅ?

ខ៖ ចាស!

ក៖ ហើយយ៉ាងម៉េចទៀតអ៊ី តើគេអោយអ៊ីទៅណាទៅនៃ?

ខ៖ រួចទៅច្រើនកន្លែងណាស់ក្មួយអើយឡើងគ្រាប់សព្វនោះ។

ក៖ ចាស! ហើយចឹងតើអ៊ីមានការលំបាកអីដែរឬទេអ៊ី?

ខ៖ លំបាកវេទនាទាំងអស់!

ក៖ ចឹងអ៊ីចេះស៊ូរួចណ៎អ៊ី?

ខ៖ ចេះតែតស៊ូទៅ! ដល់ពេលរួចមកនេះទៀត មកខាងតាកុតយើងនុងណា ដល់រួចគេបាញ់

ក៖ ចាស!

ខ៖ ហើយចឹងមីខ្ញឹមកូនតាឃួននេះណាវាដេកស្រមុក វាថាតោះទៅស្ទុងៗ
ហើយបើសិនជាទៅស្ទុងយ៉ាងម៉េចបើសិនជាគេបាញ់ហ៎!
ហើយចឹងនុងថាចឹងក៏អ៊ីរត់មកផ្ទះហ្នឹងមក ដល់ពេលរត់មកដល់ផ្ទះទទួលឆ្លងនេះ
ដែលកន្លែងរត់ដៅខ្សាច់នេះបានឆ្លងមកហើយមកជួបប្រធានភូមិពាមក្នុងនេះ!
គេបានសួរថាទៅឯណា? កូនស្លាប់! ទៅណា?

ក៖ ប្រធានភូមិនុងគាត់ឈ្មោះអី?

ខ៖ ឈ្មោះឌិន!

ក៖ ចាស

ខ៖ ហើយថាស្លាប់ហើយ ខ្ញុំត្រូវទៅផ្ទះរបស់ខ្ញុំហើយព្រោះអីគេរ៉ៃដល់ផ្ទះខ្ញុំហើយ!
គាត់ថាអោយទៅវិញ ខ្ញុំថាអត់ទៅវិញទេ! ហើយក៏រុលមកផ្ទះនុងមក។
ដល់រុលមកផ្ទះនុងចប់ហើយបានគេប្រាប់ថា នៅថ្ងៃ៧
ដូចជានៅ៧មករាហ្នឹងហើយគេអោយយើងរៀបចំទៅ ត្នោតជ្រុមនេះ
ចំកន្លែងអ៊ីកាប់រន្ធដៅជំរៅ៧ជ្រុងនុងគេអោយអ៊ីទៅឯនុង
ដល់ពេលទៅឯនុងវាចង់មីងទៅនុងហើយ រៀបចំឥវ៉ាន់ទៅហើយ។ អ៊ីថាមិនទៅនោះទេ

សុខចិត្តចូលព្រៃហើយ ដល់ពេលចូលព្រៃរួចចឹងទៅ បាន៧មករា ហ៊ុនសែននេះរំដោះបាន ហើយនៅតាមផ្លូវចឹងគេថាដាច់ហើយ ចឹងបានអីអរ នៅរស់ទាល់តែសព្វថ្ងៃហ្នឹងមក បានស្រួលធូជាងនេះហ់! ចឹងមានតែប៉ុណ្ណឹងក្មួយ។

ក៖ ចាស

ខ៖ ហ្នឹងហើយ

ក៖ ចឹងអីដាច់ពីរបបនុងហើយតើអីជួបជុំឪពុកម្ដាយបងប្អូនវិញហើយណ់អី?

ខ៖ ជួបជុំវិញហើយ! កាលនុងបានរួចពីស្លាប់ហើយ។

ក៖ ដល់ហើយអីបានប្រកបមុខរបរអ្វីទៀត?

ខ៖ ដល់ពេលរួចចឹងទៅប្រកបមុខរបរធ្វើស្រែចំការដាំត្រឡាចអីចឹងទៅ។

ក៖ ហើយចុះដីនុងអី! ជាដីរដ្ឋចែកអោយឬក៏ជាដីកេរ?

ខ៖ ជាដីរាន!

ក៖ ដីរាន!

ខ៖ ដល់ពេលដាច់ចឹងអីរាន ហើយបានដាំដុះបានចេះតែបានផលមកៗ ដល់ពេលរួចទៅ បានគាត់រាងចាស់ហើយបានអីចប់ទៅហើយបានមកដល់សព្វថ្ងៃហ្នឹង។

ក៖ចឹងអីបានមកជួបជុំគ្នាវិញពីប៉ុលពតនុង
អត់មានបងប្អូនអីបានស្លាប់នៅរបបប៉ុលពតនោះទេបងប្អូនរបស់អី?

ខ៖ បងប្អូនស្លាប់ច្រើនណាស់នៅក្នុងរបបប៉ុលពតនោះ។

ក៖ បងប្អូនបង្កើតណា!

ខ៖ បងប្អូនបង្កើតស្លាប់១ ! មើល២ ទៅ៣ នៅក្នុងប៉ុលពតនុងស្លាប់៣។

ក៖ ចាស

ខ៖ ហើយដល់ពេលម្ដាយមីងនុងប៉ុន្នាននាក់ទៀតហើយ!
មានម្ដាយមីងនោះមាន២ទៅ៣នាក់កទៀត។

ក៖ កាលស្លាប់នុងអ៊ីមានបានឃើញដេស ឬក៏យ៉ាងម៉េចបានដឹង?

ខ៖ អត់មានបានឃើញនោះទេ កាលនុងរត់បែកគ្នា វាបានបាញ់ត្រូវកន្លែងនេះ!

ក៖ នៅត្រង់ចង្កេះហ៎!

ខ៖ ហើយដល់ពេលបងមួយនាក់ទៀតនុងគេយកទៅ
ហើយដល់ពេលបងមួយទៀតគេអោយទៅដឹងស្រូវពូជ! ដឹងទាល់តែមកដល់ពេលឥឡូវ ស្រូវពូជនុង។

ក៖ ចាសយកទៅស្លាប់ចោល!

ខ៖ នុងហើយយកទៅស្លាប់ចោលហើយទៅដឹកស្រូវពូជនុងណា ។

ក៖ ហឹម ដល់ពេលដាច់នុងហើយអ៊ីបានប្រកបមុខរបរធ្វើស្រែចំការអ៊ីនេស?

ខ៖ ធ្វើស្រែចំការ!

ក៖ តើហើយដល់ពេលដាច់ចឹងទៅតើមុខរបបនុងមានបានរីកចំរើនដែសអ៊ី?

ខ៖ មានការរីកចំរើន!

ក៖ តើគេបានដាំអីគេអោយ?

ខ៖ ចេះតែដាំពោតទៅ ត្រសក់ទៅ ត្រលាចទៅបានចេះតែរីកចំរើន បានទៅៗណា។

ក៖ ចឹងលក់ទៅ យកមកផ្គត់ផ្គង់នៅក្នុងគ្រួសារនុងបានគ្រាប់គ្រាន់ចឹងហេសអ៊ី?

ខ៖ បានគ្រាប់គ្រាន់!

ក៖ ចាស! ហើយមានការលំបាកអ្វីទៀតនៅក្នុងចិញ្ចឹមជីវៈភាពនុងតើការធ្វើស្រែចំការនុង តើមានភាពរាំងស្ងួតអោយយើងលំបាកដែស?

ខ៖ លំបាកដែរនុង!

ក៖ ចឹងកាលនុងអត់មានប្រើកំលាំងអីនោះទេ?

ខ៖ អត់មានប្រើនោះទេ!ប្រើដោយកំលាំងគោ!

ក៖ អត់មានប្រើម៉ាស៊ីននោះទេ!

ខ៖ អត់ទេ! ប្រើកំលាំងដោយខ្លួនរបស់យើងនុង។

ក៖ តើយើងផ្ទាល់ហ្នឹងអឺ! ការធ្វើចំរាស់អីនុង!ដូចជាចំរាស់ស្មៅ!ដាក់ទឹកនុងនុងយកយ៉ាងម៉េច?

ខ៖ ហ្នឹងហើយ! ដាក់ទឹកអីនុងវាវេទនាណាស់ មានដង្កូវមានអី
យកមកប៉ះហើយកាលនុងវាវេទនាណាស់ទំរាំតែបានមកបាននោះ!

ក៖ ចឹងកាលនុងយ៉ាងម៉េចដែរអ៊ីអត់ហ៊ានសម្លាប់?

ខ៖ មានកាលនុងមានថ្នាំហើយតែប្រើទៅវាអត់ងាប់!

ក៖ ចា

ខ៖ ចឹងចាប់ដោយខ្លួនឯង នៅក្នុង១ថ្ងៃចឹងបានប្រហែល៤០០ទៅ៥០០ដង្កូវអីចឹងទៅណា។

ក៖ ៤០០ទៅ៥០០ដង្កូវ?

ខ៖ ជួនកាលអីឡើងដល់១០០០អីក៏មានដែរ!

ក៖ អូស! ចឹងអ៊ីអត់ខ្លាចដង្កូវ?

ខ៖ ខ្លាចដែរនុងណា!

ក៖ អូ

ខ៖ អ៊ីខ្លាចណាស់ព្រោះដង្កូវខ្លាំងធំៗ អ៊ីចាប់ដាក់ក្នុងកំប៉ុងឡើងកន្លះៗកំប៉ុង
អ៊ីខ្លាចឡើងម៉ែនទែន។

ក៖ ចឹងវាស៊ីស្លឹក!

ខ៖ ស៊ីស្លឹកឡើងរិច ចឹងបានថាលំបាកណាស់រឿងដាំដំណាំដំណូចចឹងនោះ!

ក៖ ចាស!រួចទៅរឿងជំរះស្មៅអីនឹងចប?

ខ៖ ចប នៅក្នុង១ថ្ងៃចឹងជំរះ២ជួរ
ដូចថានៅក្នុង១ថ្ងៃចឹងដល់ពេលម៉ោង១២បានរួចហើយបានមកហូបបាយ។

ក៖ ចាស

ខ៖ ហើយទៅបានទៅចាប់ចឹង!

ក៖ ដាក់កំរិតខ្លួនឯងចឹងដែរ

ខ៖ ដាក់កំរិតខ្លួនឯង!
ហើយដល់ពេលល្ងាចទៅដាក់កំរិតខ្លួនឯង២ជួរទៀតហើយដល់ពេលល្ងាចឡើងបានចុះ !
ចុះនុងនៅម៉ោង៥។

ក៖ ចា

ខ៖ ចឹងបានហើយ! ដល់ពេលហើយហូបបាយហើយបានមកតែម្តង
ដាក់កំរិតខ្លួនឯងចឹងណា។

ក៖ ចាសហើយចឹងអីបានធ្វើបាយហើយចឹងទូលយកទៅ?

ខ៖ ដាក់ទូក!

ក៖ ជិះទូកទៅហោស?

ខ៖ ជិះទូកទៅណា

ក៖ ចឹងមិនមែនដើរនោះទេ

ខ៖ វេទនាណាស់ទើបតែមកដល់ពេលឥឡូវនេះនោះទេរាងស្រួល!

ក៖ ចុះអីស្រែចំការនុងអត់មានភ្លួរដីអីនោះទេហេសអី?

ខ៖ អត់មានភ្ជួរអីនោះទេ បុករន្ធដៅដាំ! ធ្វើស្មៅជំរាស់អាស្មៅមួយជួរៗនៅមុខនុង ឡើងស្អាតឆិនចឹងណា ហើយបានបុកដាក់គ្រាប់ត្រឡាច ។

ក៖ បានដាក់តាមជួរចឹងទៅណ៎?

ខ៖ ហ្នឹងហើយ!ដាក់ត្រឡាចទៅ ហើយដល់ពេលត្រឡាចនុងចឹងទៀតគឺថាយើងធ្វើកន្ទោងបណ្តុះឡើងបានវែងៗនេះ ដល់ហើយបានយើងដាក់ដាំទៀតណា។

ក៖ ចាសចឹងផ្សាំបណ្តុះវាទៅសិនហើយបានជាកូនហើយបានយើងយកទៅបណ្តុះនៅឯនុងហោស?

ខ៖ ហ្នឹងហើយ!

ក៖ ចឹងហើយបានជាយើងដាក់ដាំ?

ខ៖ ដាក់ដាំនៅឯនុងដែរ។

ក៖ អូ!ចាស!

ខ៖ កាប់រន្ធដៅដាក់ដាំ!

ក៖ ចឹងអ៊ីមានបានចង់ចាំដែរឬទេថា ពេលនុងត្រឡាចនុងគេលក់រាប់ជា?

ខ៖ គេរាប់ជាល្ង នៅមួយល្ងនុង១២!

ក៖ ១២ផ្លែ!

ខ៖ ហ្នឹងហើយ១ល្ង ១២ផ្លែ ២៥!

ក៖ ២៥០០រៀល

ខ៖ ហ្នឹងហើយ

ក៖ ចឹងយកទៅលក់នៅឯណាដែរទីផ្សារ?

ខ៖ គេមកយកនៅឯហ្នឹង!

ក៖ គេមកយកនៅឯផ្ទះហ្នឹង?

ខ៖ ហ្នឹងហើយ!

ក៖ ចឹងមិនលំបាកទៅរកទីផ្សារអីនោះទេ!

ខ៖ វាលំបាកចែៃកក្មួយអើយ!
គឺយើងត្រូវជញ្ជូនយកមកពីកំពង់ឡើងចង់ដាច់ជើងនេះអស់ទៅហើយ
ថាយ៉ាប់ណាស់ក្មួយអើយ!

ក៖ ក៏ប៉ុន្តែបានប៉ុន្មានដែរ?

ខ៖ បាន១០០ឡូអីដែរ!

ក៖ ចាសៗ១០០ឡូបានច្រើនដែរ!

ខ៖ នុងហើយបានច្រើនដែរនៅក្នុង១ថ្ងៃហ្នឹង បាន២០ម៉ឺនអី បាន៣០ម៉ឺនអីដែរ។

ក៖ ចាស

ខ៖ចឹងបានហើយ!

ក៖ ចឹងបើសិនជា១០០ឡូបាន២៥ម៉ឺន?

ខ៖ ហ្នឹងហើយ!

ក៖ចឹងដាក់ទូក !

ខ៖ គេដាក់ទូកនុងយកពីចំការមក !

ក៖ ចាស

ខ៖
ដាក់ទូកយកមកហើយបានឡើងមកលើច្រាំងនុងហើយក្មេងទូលមកឡើងមកលើច្រាំងនេះ យ៉ាប់តែហ្នឹងណាព្រោះអីវាទូលពេក!

ក៖ ចុះតើគេមានបានដាំអីគេទៀតដីនុង?

ខ៖ អត់មានបានដាំអីគេទៀតនោះទេដីនុងព្រោះអីគាត់បានចាស់ណាស់ទៅហើយ គាត់ទៅអត់រួចកំលាំងវាអត់រួចចឹងក៏ឈប់តែម្តងទៅ។

ក៖ អត់នោះទេ ចង់ដឹងកាលអ៊ីនៅពីក្មេងនុងអ៊ី ដូចថាដាំត្រឡោចរួចហើយតើនៅកន្លែងនុងមានបានដាំត្រឡោចទៀតអត់?

ខ៖ អត់នោះទេ!

ក៖ ចឹងតែ១មុខនុងទេហេស?

ខ៖ ដល់រួចទៅវាដាំអត់ល្អ បានត្រឡោច១នុង ដល់ពេលដាំអីទៀតអត់កើត ដូចដាំម្ទេសអីអត់កើតចឹងទៅ ខាតអស់ឡើងប៉ុន្មានលានហើយចាស។

ក៖ អូចាស! ចឹងបន្តពីនុងមករហូត តើអ៊ីមានការព្យាយាមធ្វើអ្វីទៀតដេស?

ខ៖ អត់មានធ្វើអីនោះទេ បានធ្វើតែចំការនោះតែមួយមុខបានចប់ចឹងទៅ ហើយកូននោះបានមើលត្រីមើលអីចឹងមានតែប៉ុណ្ណឹង!

ក៖ចឹងកាលនុងខ្ញុំដូចបានដឹងអ៊ីដូចបានធ្វើការងារឃុំដែរ?

ខ៖ អូ! អារឿងថាបានធ្វើការងារឃុំនោះគឺធ្វើសមាគមន៏ឃុំ!

ក៖ សមាគមន៏ឃុំចឹងហេស?

ខ៖ សមាគមន៏ភូមិឃុំជាមួយនឹងអ៊ីគីមនេះ។

ក៖ ចាស!

ខ៖ ហ្នឹងហើយ

កៈចឹងអ៊ីអត់ចេះអក្សរទេតែគេអោយធ្វើនៅក្នុងសមាគមន៍ហ្នឹង?

ខៈ អ៊ីអត់ចេះនោះទេ តែអ៊ីបានចូលធ្វើការងារនៅដោយសារអ៊ីចេះកត់ឈ្មោះ ប៉ុន្តែដូចថាមានអីៗចឹងអ៊ីកត់បាន មើលអក្សរអីចឹងទៅ មើលដាច់ តែថាឈ្មោះអីអាចបាន។

កៈ ចឹងពាក្យណាស្រាលៗអីនោះគឺថាអាចធ្វើបាន!

ខៈ អាចបាន! ដូចថាទៅរ៉ៃលុយគេ១០០អីចឹងទៅ កត់ដាក់ឈ្មោះគេ១០០អីចឹងទៅ។

កៈ ចាស

ខៈ ដល់ដាក់គេចឹងទៅក៏បានប្រាប់ឈ្មោះគេទៅ!

កៈ ចាស

ខៈ
ចឹងអ៊ីចំណាប់ណាស់ចឹងអត់មានបានចូលរៀននៅសាលាផងបានចូលធ្វើការងារនៅក្នុងភូមិឃុំ
!

កៈ
ហ្នឹងហើយ!មកដល់ពេលឥឡូវនេះអ៊ីមានបានចាំឆ្នាំថាអ៊ីបានចូលធ្វើការងារនៅភូមិឃុំនុងនៅឆ្នាំណា?

ខៈ មិនបានដឹងថានៅក្នុងឆ្នាំណានោះទេ គឺថាដឹងថានៅក្នុងជំនាន់តាហ្វ!

កៈ ចឹងមិនមែនតាសៀមនោះទេហេស? បើសិនជាតាសៀមនោះគឺខ្ញុំចាំ!

ខៈ តាសៀមនុងចាំ!

កៈ ចឹងនៅរដ្ឋកម្ពុជានុងនៅឡើយនោះទេចឹង!
ហើយចឹងដល់ពេលតាហ្វបនេះនៅសាធារណៈរដ្ឋកម្ពុជាហើយដល់ពេលតាសៀមបានអ៊ី!
រដ្ឋកម្ពុជា?

ខៈ ហ្នឹងហើយតាសៀម!

កៈ ចាស

ខៈ ហើយបានមកតាត្រាស់ទៀតណា!

កៈ អូចាស!

ខៈតាត្រាស់នេះក្រោយនោះទេ!

កៈ ចឹងគាត់នៅក្នុងរដ្ឋកម្ពុជាដែរ?

ខៈ ហ្នឹងហើយសុតតែនៅក្នុង!

កៈ ហើយចឹងអ៊ីឈប់ធ្វើការហ្នឹងវិញនៅឆ្នាំណាអ៊ីមានបានដឹងដែស?

ខៈ អ៊ីបានឈប់ធ្វើការដោយសារតែអ៊ីបានមកធ្វើការងារនៅសមាគមន៍ហ្នឹង។

កៈ តើមូលហេតុអ្វីបានជាអ៊ីឈប់ធ្វើការងារហ្នឹងវិញ?

ខៈ ឈប់នុងដោយសារតែអ៊ីបានមានគ្រួសារទៅនៅខាងផ្ទះប្តី?

កៈ នៅឯណាដែរផ្ទះប្តីនុង?

ខៈ នៅឯខាងបឹងធំ!

កៈ អូ

ខៈ ហ្នឹងហើយ

កៈ ចឹងអ៊ីតើគេបានអោយប្រាក់ខែបានប៉ុន្មានដែរ?

ខៈ ប្រាក់ខែគឺថាបានគេជួយមកបាន២០០០ទៅ បាន៣០០០ទៅ ជួនអីកាលបាន៥០០០ទៅ។

កៈ នៅក្នុង១ខែហោស?

ខៈ នៅក្នុង១ខែហ្នឹងណាគេអោយទៅ!

កៈ ចាស

ខ៖ ហើយដល់ពេលដល់ខែចឹងគេក៏បានបើកអោយអំណោយអោយចឹងទៅ ដូចជាប្រេងកាតទៅ ដូចជាគ្រាប់ ស្អីទេ! ហើយហ្នឹងអង្គជោសាលីនោះ។

ក៖ ចាសអង្គជោសាលី!

ខ៖ ហ្នឹងហើយបានចឹងបើសិនជាប្រាក់ខែនោះវាគ្មាននោះទេ តែគេបានអាណិតចឹងគេចេះតែអោយទៅ។

ក៖ ចាគេបានប្រាក់នុងមកពីណាមកបានគេអោយអឺបាន?

ខ៖ អានុងប្រាក់សមាគមន៍នុង!

ក៖ អូ!

ខ៖ បានមកពីសមាគមន៍នុងមក ហើយបានថាដល់ពេលនុងមកបានគេចែកអោយគ្នាចាយទៅ ។

ក៖ ចឹងបានគ្នាប្រឹងធ្វើការទៅ!

ខ៖ នុងហើយចឹងបានគ្នាប្រឹងធ្វើការនឹងទៅ។

ក៖ ចាស

ខ៖ ហ្នឹងហើយ

ក៖ចឹងដូចថាអឺបានធ្វើការនុងបានមួយរយៈហ្នឹង តើអឺដូចថាមានជួបការលំបាកអ្វីគេខ្លះដែរ ចំពោះបុគ្គលិតដែលធ្វើការងារជាមួយនឹងគ្នានុង?

ខ៖ នុងអត់មានអីនោះទេ ដូចជាធម្មតានុង!

ក៖ ចឹងចេះតែដូចជាសុខសាន្តជាមួយនឹងគ្នាមករហូតអត់ដែរមានបញ្ហាអីនោះទេអឺ?

ខ៖ ហ្នឹងហើយ!អត់មាននោះទេដល់ពេលរួចចឹងទៅក៏ប្រធានភូមិនេះបានអោយអឺធ្វើអនុ! បានជាអនុប្រធានភូមិចឹងទៀតទៅណា!

ក៖ ចាស!

ខ៖ ហើយបានទៅប្រជុំនៅឯស្រុកទៀតណា

ក៖ ចា

ខ៖ នុងហើយដល់ពេលចឹងនុងគាត់អោយមើល! គាត់អោយ៣០០០ដែរ គ្រាន់តែទៅចឹង ពួកប្រធានគេបានថា ចុះនេះនារីនេះ
ប្រុសទាំងអស់ហើយនារីតែម្នាក់ឯងហើយក៏ប៉ុននិយាយស្ដីម្លេះ!

ក៖ ចាស

ខ៖ ពេលនុងគេសួរត្រង់ថាផែនការណ៏ត្រូវធ្វើយ៉ាងម៉េច ហើយត្រូវបង្កបង្កើតផលយ៉ាងម៉េច ពេលនុងអីឆ្លើយទៅ! ហើយត្រូវ។

ក៖ចឹងអីរៀបហើយឡើងឆ្លើយទៅ?

ខ៖ ឡើងឆ្លើយទៅ!ដូចថាប្រជុំហើយនៅក្នុង១ក្រុមៗចឹងដូចថាមាន១២នាក់
អីឆ្លើយហើយដូចថានៅក្រោយចឹងធ្វើការបានបង្កបង្កើតផលដូចជាស្នូងស្រែអី
ដែលធ្វើសមាគមន៍ទៀត ហើយមានកងទ័ពសម្ងហាភូមិនៅមុខដល់ពេលអស់កំលាំងចឹង
ដែលនារីចុះក្រោយនុង ផ្តល់អោយមានដូចជាស្ករគ្រាប់បានមានទឹកមាត់អីដែល!
ចឹងគេថានារីនេះគ្រាន់បើចេះឆ្លើយត្រូវ។

ក៖ ហេសៗចាស!

ខ៖ ចេះឆ្លើយត្រូវណា!

ក៖ ចឹងបានមានកំលាំងបន្តិចទៅ យកមកបៀមទៅមានកំលាំងស្ករគ្រាប់!

ខ៖ ចាសបានស្ករគ្រាប់ផ្តល់អោយចឹងគ្នាមិនស្ងួតទឹកមាត់ដល់ហើយចឹងទៅ ថាហាក់ !!
ចឹងនារីនោះគ្រាន់បើ! ទៅនុងបាន៣ថ្ងៃណា ហើយគេអោយសរសេរ
តែធ្វើប្រាប់គេថាខ្ញុំអត់ចេះនោះទេតែថាបើសិនជាអោយខ្ញុំឆ្លើយនោះគឺខ្ញុំអាចឆ្លើយបាន។

ក៖ ចាសៗ

ខ៖ ហើយដល់ពេលនុងគេបានសរសើរថាគ្រាន់បើ មើលអនុប្រធាននេះគ្រាន់បើគេថាចឹងណា។

ក៖ ចាសហើយចឹងអ៊ីរួចដល់ពេលនុងមកបានរៀបអាពាហ៍ពិពាហ៍ក៏បានឈប់ពីការងារនុងមកចឹងហោសអ៊ី?

ខ៖ ហ្នឹងហើយថាចាស!

ក៖ចឹងអ៊ីមុននឹងបញ្ចប់តើអ៊ីដូចថាមានមតិនិងយោលបល់អ្វីដើម្បីផ្តាំផ្ញើដល់កូន ដល់ចៅនឹងដល់ប្អូនៗជំនាន់ក្រោយ?

ខ៖ ខ្ញុំសូមផ្តាំផ្ញើដល់ចៅៗជំនាន់ក្រោយនុងយកដំរាប់ទៅតាមជីដូននុងមើលថាវាលំបាកវេទនាយ៉ាងណានឹងមានតែប៉ុណ្ណឹងនោះទេ ! អត់មតិហើយ។

ក៖ ចាសខ្ញុំសូមអរគុណ! អ៊ីច្រើនដែលបានខិតខំលះបង់ពេលវេលាអោយខ្ញុំធ្វើការសម្ភាសពីជីវៈប្រវត្តិរបស់អ៊ីណាអ៊ី!

ខ៖ ចា

ក៖ ចឹងខ្ញុំសុំដាក់ការសម្ភាសនេះទៅខាងសកលវិទ្យាល័យBYUនៅខាងUSAតើអ៊ីអនុញ្ញាតអោយក្មួយយកទៅដាក់នៅលើគេហៈទំព័រនេះទេ?

ខ៖ យកទៅដាក់ទៅ! អនុញ្ញាតអោយក្មួយយកទៅដាក់។

ក៖ ចឹងហោស!

ខ៖ ហ្នឹងហើយ

ក៖ ចឹងខ្ញុំសូមជូនពរអ៊ីអោយមានអាយុវណ្ណៈសុខៈពាលៈកុំម្បីឃ្លានឃ្លាតឡើយ!

ខ៖ ចាស ក្មួយឯងក៏ចឹងដែរអោយមានអាយុវែង!

ក៖ ចាសចឹងខ្ញុំសូមជំរាបលាណាអ៊ី!

ខ៖ អើ! សុខសប្បាយ!